# Smallpox

## តើអុតធំមានការគំរាមកំហែងទំហំប៉ុន្មាន?

លក្ខណៈនៃការគ្រុនក្តៅនិងរោលស្បែក រោគអុតធំ ជារោគមួយដែលគំរាមកំហែងសុខភាព ដែលមនុស្សលោកជួបប្រទះ។ រោគអុតធំ បណ្តាលមកពីមេរោគ ដែលធ្លាប់សំលាប់មនុស្ស១ភាគ៣នៃមនុស្សនៅតំបន់ដែលមានរោគនេះកើតឡើង។



*ជួសថ្នាំការពាររោគអុតធំ*

ក៏ប៉ុន្តែ មកទល់នឹងឆ្នាំ១៩៨០ អុតធំត្រូវបានកំចាត់ចោលដោយសរវតិភាព ដែលជារោគមួយបណ្តាជនមានការព្រួយបារម្ភ។ មានសេចក្តីអំណរគុណដល់មហាយុទ្ធនាការដែលបានដឹកនាំដោយអង្គការសុខភាពសកលលោក។ ជម្ងឺដែលបានដឹងចុងក្រោយបង្អស់នៅពិភពលោកនេះ បានឃើញមាននៅចុងឆ្នាំ១៩៧០។ តាំងពីនោះមក គ្មានសត្វណាមួយក្រៅពីមនុស្សបានដឹងថាមានរោគ រឺចម្លងរោគនេះឡើយ។ ភាពគ្រោះថ្នាក់នឹងឆ្លងរោគនេះ ត្រូវបានបន្ថយមកដល់សូន្យ។

ដោយព្រិត្តិការណ៍មិនល្អ អុតធំមិនបានកំចាត់ឲ្យអស់ពូជនោះទេ ត្រូវគេបានរក្សាទុកមួយចំនួនតូច សំរាប់ការប្រើក្នុងមន្ទីរពិសោធ បន្ទាប់ពីជម្ងឺបានកំចាត់រួច ហើយឥឡូវនេះ មានការជឿថាមេរោគនោះ បានយកមកកែប្រែប្រើជាអាវុធមួយ។ ការកើតឡើងអាសន្នរោគអុតធំ បណ្តាលមកពីការបញ្ចេញប្រើវាដោយចេតនា ឥឡូវនេះគេគឹតថា វានឹងអាចកើតឡើងពិត។ ការវាយប្រហារដោយប្រើអុតធំពីក្រុមភាវរកម្មនោះតិចតួចណាស់។ ក៏ប៉ុន្តែលិទ្ធផលនៃការប្រហារប្រសិនបើកើតឡើងនោះ វានឹងមានសភាពធ្ងន់ធ្ងណាស់។

## តើរោគសញ្ញានៃរោគអុតធំមានអ្វីខ្លះ?

រោគសញ្ញានៃអុតធំ ចាប់ផ្តើមដោយគ្រុនក្តៅខ្លាំង ឈឺចុកចាប់ក្បាលនិងខ្លួនប្រាណ និងចំពោះជំងឺខ្លះ ក្អួត។ បន្ទាប់ពី២ទៅ៤ថ្ងៃ រមាស់លើស្បែកកើតឡើង និងរាលដាល កើតទៅជាឡើងកន្ទួលដុំៗនិងរបកស្បែកក្រៀម។ បន្ទាប់ពីស្បែកក្រៀមនោះជ្រុះរួច ទុកនៅស្លាកស្នាមតូចៗ។

## តើអស់រយៈពេលប៉ុន្មានដែលអុតធំកើតឡើងនៅពេលដែលឆ្លងភ្លាម? ហើយនៅពេលណាដែលអ្នកអាចទឹងចំលងដល់មនុស្សឯទៀត?

រោគសញ្ញានៃរោគអុតធំ ធម្មតាចេញឲ្យឃើញប្រហែលជា១២-១៤ថ្ងៃ បន្ទាប់ពីមនុស្សម្នាក់បានឆ្លងជម្ងឺនេះ ទោះបីជារោគសញ្ញាចេញឲ្យឃើញយ៉ាងលឿន៧ថ្ងៃ និងយ៉ាងយូរ១៧ថ្ងៃក៏ដោយ។ នៅពេលរោគសញ្ញាចេញឲ្យឃើញភ្លាមនោះ អ្នកជម្ងឺឈឺធ្ងន់ណាស់ក្នុងការធ្វើដំណើរ រឺធ្វើសកម្មភាពភាគច្រើន។ អ្នកជម្ងឺមិនអាចចម្លងរោគបានទេ ទល់តែសញ្ញារោលរមាស់កើតឡើង។

## តើរោគអុតធំមានកម្លាំងឆ្លងទំហំប៉ុន្មាន?

រោគអុតធំឆ្លងណាស់ ប៉ុន្តែវាឆ្លងមិនងាយដូចជម្ងឺគ្រុនផ្តាស់សាយ រឺជម្ងឺកញ្ជ្រិលទេ។ តាមធម្មតា វាឆ្លងតាមបែបការទាក់ទងដ៏យូរនិងនៅជិត មុខទល់នឹងមុខ ដូចជាការនៅផ្ទះជាមួយគ្នាក្នុងការចម្លងពីម្នាក់ទៅម្នាក់ទៀត។ វាក៏អាចឆ្លងតាមរយៈទឹកខ្លួនប្រាណ រឺរបស់ដូចជាកំរាលពូកនិងសំលៀកបំពាក់។ វាក៏អាចឆ្លងខ្យល់អាកាសដែលនៅក្នុងអាគារ រឺទីលំហរដែលបិទបាំងជិត ទោះបីជាការកើតឡើងនោះធម្មតាវាមានតិចក៏ដោយ។

## តើមានការព្យាបាលសំរាប់អុតធំរឺទេ?

នៅបច្ចុប្បន្ននេះ គ្មានការព្យាបាលដែលមានប្រសិទ្ធភាពទល់នឹងអុតធំទេ។ ក៏ប៉ុន្តែអាចការពារកុំឲ្យមានរោគនេះបាន តាមរយៈចាក់ថ្នាំការពារ។

ថ្នាំចាក់ការពារនៅតែអាចការពារមនុស្សបាន បន្ទាប់ពីបានឆ្លងមេរោគអុតធំរួចហើយក៏ដោយ។ នៅពេលដែលគ្មានថ្នាំការពារអាចផ្តល់ការការពារមួយភាគរយក៏ដោយ ការចាក់ថ្នាំនៅក្នុងរវាង៣ថ្ងៃដែលបានប៉ះនឹងអុតធំនោះ វាអាចផ្តល់ក៏រិតការពារដូចគ្នានិងការចាក់ថ្នាំ*មុនពេល*ដែលអ្នកបានប៉ះពាល់មេរោគនោះ។ ការចាក់ថ្នាំការពារក្នុងរវាង៧ថ្ងៃ នឹងបន្ថយភាពធ្ងន់ធ្ងរនៃជម្ងឺនេះ លទ្ធផលមកពីការប៉ះពាល់នឹងអុតធំ។

MINNESOTA MDH DEPARTMENT OF HEALTH
Communications Office
625 North Robert Street/Box 64975
St. Paul, MN 551164-0975
(651) 201-4989
www.health.state.mn.us

# Smallpox – ទំព័រទី 2

ទោះជាយ៉ាងណាក៏ដោយ ថ្នាំការពារអាចបណ្តាលឲ្យមានការទាស់ខ្លាំងដល់មនុស្សខ្លះ។ ដូច្នេះផលប្រយោជន៍ថ្នាំការពារ ត្រូវការយកមកថ្លឹងនឹងផលពិបាក។ ***យ៉ាងតិចណាស់*** មានការគណនាថា ម្នាក់ក្នុង១លាននាក់ដែលទទួលការចាក់ថ្នាំ នឹងស្លាប់ និង១៥នាក់ទៀតនឹងធ្លាក់ខ្លួនឈឺធ្ងន់។ និងលើកលែងតែនរណាមួយ*ប្រើ*រោគនេះជាអាវុធ ការគ្រោះថ្នាក់នឹងមានជម្ងឺអុតធំ វា*គ្មានទាល់តែសោះ*។